ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៤០..សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មាធិការនៃគណៈកម្មាធិការ
## ចម្រុះកិច្ចការព្រំដែនគោក កម្ពុជា-ថៃ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៣១/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៧ សសរ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ថៃ
- បានឃើញតម្រូវការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**ប្រការ១÷** បង្កើតអនុគណៈកម្មាធិការនៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនគោក ដែលមានសមាសភាពដូចតទៅ:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកឧត្តម នាង ផាត | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣- | ឯកឧត្តម ព្រុក សារឿន | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៤- | ឯកឧត្តម | ជា ម៉ន | មេបញ្ជាការយោធិភូមិភាគ៤ | សមាជិក |
| ៥- | ឯកឧត្តម | ម៉ុន សេខ | មេបញ្ជាការយោធិភូមិភាគ៥ | សមាជិក |
| ៦- | ឯកឧត្តម | អ៊ិត សុត្ថា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- | ឯកឧត្តម | ហេង រតនា | អគ្គនាយក នៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា | សមាជិក |
| ៨- | ឯកឧត្តម | ប្រាក់ សំអឿន | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលទូទៅ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | ឯកឧត្តម | ស៊ា ម៉ៅ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០- | ឯកឧត្តម | ខេង សុមេធ | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១១- | ឯកឧត្តម | ឡាយ សៀងលី | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១២- | ឯកឧត្តម | ស៊ិន សុធានី | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ១៣- | ឯកឧត្តម | គង់ ច័ន្ទវាសនា | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក និងជាលេខាធិការ |
| ១៤- | ឯកឧត្តម | ហាក់ សុខហេង | អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក និងជាលេខាធិការ |
| ១៥- | លោក | កែវ ទិសិដ្ឋ | ប្រធាននាយដ្ឋានច្បាប់ និងកុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦- | លោក | ម៉ុន សុខទិបុល | អគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ | សមាជិក |
| ១៧- | លោកស្រី | ឡាយ ច័ន្ទរស្មី | អនុប្រធាននាយកដ្ឋានអាស៊ី១ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨- | លោក | ជា សម្បត្តិ | ប្រធានការិយាល័យកិច្ចការព្រំដែននៃនាយដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ២**÷អនុគណៈកម្មាធិការ នៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនគោកកម្ពុជា-ថៃ មានភារកិច្ចដូចតទៅ÷

(ក) ជាយន្តការឆ្លើយតប ក្នុងកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រថៃ ក្នុងដំណើរការចរចាកិច្ចការព្រំដែនដែលកំពុងប្រព្រឹត្តទៅ។

(ខ)- ជាយន្តការទំនាក់ទំនងសមភាគី ក្នុងកិច្ចការព្រំដែនជាមួយអនុគណៈកម្មាធិការថ្មី ដែលភាគីព្រះរាជាណាចក្រថៃទើបតែបានបង្កើតឡើង។

(គ)- ទទួលព័ត៌មានពីអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ថៃ ដើម្បីផ្តល់ការសម្របសម្រួលដល់ដំណើរការកិច្ចការចរចាកម្ពុជា-ថៃ ដែលកំពុងប្រព្រឹត្តទៅ។

**ប្រការ៣**÷សមាជិកនៃអនុគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន។

**ប្រការ៤**÷ អនុគណៈកម្មាធិការនេះមានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥**÷ អនុគណៈកម្មាធិការនេះ អាចស្នើសុំមូលនិធិសម្រាប់កិច្ចប្រជុំ រួមទាំងការចំណាយផ្សេងៗ និងឧបករណ៍ សម្ភារៈចាំបាច់នានា ក្នុងការបំពេញបេសកកម្ម។

**ប្រការ៦**÷ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com